## Saying “I don’t understand”



១ បញ្ញា៖ お早う!
ធារី៖ ស្អីគេ បញ្ញា? និយាយអីគេហ្នឹង? ស្ដាប់អត់បានទេ។
បញ្ញា៖ ភាសាជប៉ុនហ្នឹងណា។
ធារី៖ (ចុះពាក្យមិញ)បានន័យថាម៉េច?
បញ្ញា៖ មានន័យថា / ប្រែថា អរុណសួស្ដី។

២ សុភា៖ កញ្ញា ជួយមើលដំណោះស្រាយលំហាត់នេះតិចមើល យល់អត់?
ម៉េចក៏ចម្លើយចេញបែបហ្នឹងវិញ?
កញ្ញា៖ អឺម... ខ្ញុំដូចអត់យល់ដែរ។ ត្រង់នេះម៉េចក៏សុខៗទៅជាអញ្ចេះវិញ?
សុភា៖ ហ្នឹងហើយ ខ្ញុំអត់យល់ត្រង់ហ្នឹងដែរ។

៣ ធារី៖ បងតារា ម៉េចក៏បង ... ?
តារា៖ ព្រោះ ...។ យល់អត់ / យល់នៅ?
ធារី៖ អូ អីចឹងទេ ខ្ញុំយល់ហើយ!
តារា៖ ទាល់អីចឹងបានយល់!

៤ ធារី៖ បងតារា ម៉េចក៏បង ... ?
តារា៖ ព្រោះ ...។ យល់អត់ / យល់នៅ?
ធារី៖ អត់យល់!
តារា៖ អត់យល់អត់ទៅ!

| | | | |
|---|---|---|---|
| ស្អីគេ? = អីគេ? | What? | ចម្លើយ | answer |
| អីគេហ្នឹង? | What is that? | សុខៗ | suddenly |
| ស្ដាប់អត់បាន | I didn’t get (what you’ve just said) | អញ្ចេះ | spoken form of បែបនេះ |
| មិញ = អម្បាញ់មិញ | just now | ត្រង់ហ្នឹង = ត្រង់នេះ | this point |
| អរុណសួស្ដី | Good morning! (formal) | អូ អីចឹងទេ! | Oh, I see! |
| ដំណោះស្រាយ | solution | ទាល់អីចឹងបានយល់! | Finally, you’ve understood it! |
| ម៉េចក៏ ... ? | Why is it that ... ? | អត់យល់អត់ទៅ! | If you don’t understand, your problem! |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

## Cultural notes

ជាទូទៅ ការសួរបញ្ជាក់ក្រោយការពន្យល់អ្វីមួយថា "តើអ្នកយល់ទេ?" មិនមែនជាការគួរសមប៉ុន្មានទេ។ ការគួរសមបំផុត គឺ ក្រោយពេលពន្យល់អ្វីមួយ គួរនៅស្ងៀម និងញញឹមទៅកាន់ដៃគូសន្ទនា។ ពិតប្រាកដណាស់ ការធ្វើបែបនេះ យើងមិនដឹងប្រាកដថា ដៃគូសន្ទនាពិតជាយល់អ្វីដែលយើងបាននិយាយ ឬពន្យល់នោះឡើយ។ ផ្ទុយទៅវិញ ក្នុងករណីដែលមានអ្នកសុំការពន្យល់ (= ចង់ឲ្យយើងពន្យល់) ដូចជាពន្យល់មេរៀន ឬរបៀបប្រើអ្វីមួយ ការសួរបញ្ជាក់ច្រើនដងដូចជា "ត្រង់ហ្នឹង/កន្លែងហ្នឹង យល់អត់?" ជាការធម្មតា។

| | |
|---|---|
| សួរបញ្ជាក់ | to confirm |
| ការពន្យល់ | explanation |
| នៅស្ងៀម | to keep silent |
| ដៃគូសន្ទនា | conversation partner |
| ពិតប្រាកដណាស់ | of course |
| មិនដឹងប្រាកដ | [we are] not sure [whether] |
| ផ្ទុយទៅវិញ | on the contrary |
| ក្នុងករណីដែល | in case that, on the occasion that |
| ... ជាការធម្មតា | ... is normal |

## Additional dialogue

កញ្ញា៖ ធារី លំហាត់នេះ 2 + 2 x 3 ម៉េចក៏ស្មើនឹង 8 អីចឹង? មិនមែនស្មើ 12 ទេហ?

ធារី៖ មើល! អូ បើមានសញ្ញាបូក ហើយសញ្ញាគុណអីចឹង យើងត្រូវធ្វើវិធីគុណមុន។

កញ្ញា៖ អត់យល់!

ធារី៖ មានន័យថា យើងត្រូវយក 2 គុណនឹង 3 មុន។ អីចឹងវាមិនស្មើនឹង 6? រួចហើយ បានយកទៅបូកនឹង 2 តាមក្រោយ។ អីចឹង 6 បូកនឹង 2 វាមិនស្មើនឹង 8?

កញ្ញា៖ អូ អីចឹងទេ! យល់ហើយ!

| | |
|---|---|
| មិនមែន ... ទេហ? = មិនមែន ... ទេឬ? | Isn't it ... ? |
| សញ្ញាបូក | plus sign |
| សញ្ញាគុណ | multiplication sign |
| វិធីគុណ | multiplication |
| តាមក្រោយ | later |
| អីចឹងទេ! | I see! |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.